# ភាសាអង់គ្លេសជាភាសាបន្ថែម (EAL)៖ ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

សាលារៀនរដ្ឋទាំងអស់ក្នុងរដ្ឋវិចថូរៀ បង្រៀនកម្មវិធីសិក្សារដ្ឋវិចថូរៀ F-10។ កម្មវិធីសិក្សាកំណត់នូវអ្វីដែលកុមារគ្រប់រូបគួររៀនពីថ្នាក់មូលដ្ឋាន ទៅថ្នាក់ទី 10។

នៅក្នុងកម្មវិធីសិក្សារដ្ឋវិចថូរៀ F-10 កម្មវិធីសិក្សាភាសាអង់គ្លេសរួមបញ្ចូលវិស័យសិក្សាពីរ៖ ភាសាអង់គ្លេស និងភាសាអង់គ្លេសជាភាសាបន្ថែម (EAL)។

EAL គឺសម្រាប់សិស្សដែលនិយាយភាសាផ្សេងនៅផ្ទះ ហើយត្រូវការរៀនភាសាអង់គ្លេសដើម្បីជោគជ័យនៅសាលា។ នៅក្នុង EAL សិស្សរៀនអំពីភាសាអង់គ្លេស និងប្រើប្រាស់ភាសាអង់គ្លេសដើម្បីរៀនពីខ្លឹមសារ និងប្រធានបទដែលមាននៅក្នុងវិស័យរៀនសូត្រផ្សេងទៀត។ ពួកគេមានតម្រូវការរៀនសូត្រខុសៗគ្នា ពីសិស្សដែលនិយាយភាសាអង់គ្លេសនៅផ្ទះ ហើយជាភាសាដំបូងរបស់ពួកគេ។

## មាគ៌ាកម្មវិធីសិក្សា EAL

កម្មវិធីសិក្សា EAL ពិពណ៌នាអំពីមាគ៌ាបីនៃការរៀនសូត្រសម្រាប់អ្នករៀន EAL ដែលទាក់ទងនឹងអាយុ និងកម្រិតថ្នាក់របស់ពួកគេ៖

- មាគ៌ា A សម្រាប់សិស្សក្នុងថ្នាក់មូលដ្ឋាន ទៅថ្នាក់ទី 2
- មាគ៌ា B សម្រាប់សិស្សក្នុងថ្នាក់ទី 2 ដល់ថ្នាក់ទី 8
- មាគ៌ា C សម្រាប់សិស្សក្នុងថ្នាក់ទី 7 ដល់ថ្នាក់ទី 10។

មាគ៌ានីមួយៗទាំងនេះ ពិពណ៌នាអំពីអ្វីដែលសិស្សអាចធ្វើបាននៅថ្នាក់ផ្សេងៗគ្នា ដូចជា 'ធ្វើតាមការណែនាំ និងសំណួរដែលសរសេរសាមញ្ញៗ។' សិស្សរីកចម្រើនតាម និងរវាងមាគ៌ាទាំងនេះ នៅពេលដែលពួកគេរៀនភាសាអង់គ្លេស។

## តើវាត្រូវចំណាយពេលប៉ុន្មាន?

មិនមានកំណត់ ឬចំនួនពេលវេលាដែលតម្រូវ ដែលសិស្សគួររៀន ឬឈប់ការរៀន EAL នោះទេ។ ការស្រាវជ្រាវបង្ហាញថាវាអាចចំណាយពេលពី 5 ទៅ 7 ឆ្នាំ ហើយជួនកាលរហូតដល់ទៅ 10 ឆ្នាំ សម្រាប់សិស្សដើម្បីរៀនភាសាសិក្សាដែលពួកគេត្រូវការនៅអនុវិទ្យាល័យ។ មានកត្តាជាច្រើនដូចជា អាយុរបស់សិស្សនៅពេលពួកគេចាប់ផ្តើមរៀនភាសាអង់គ្លេស ដែលកំណត់ថាតើ EAL ឬភាសាអង់គ្លេសគឺជាជម្រើសដ៏ល្អបំផុតសម្រាប់សិស្សឬក៏អត់។ សិស្សមានវ័យចំណាស់ដែលចាប់ផ្តើមរៀនភាសាអង់គ្លេស នឹងត្រូវការពេលវេលាបន្ថែមទៀតដើម្បីឈានដល់កម្រិតភាសាសិក្សា ដូចគ្នានឹងសិស្សដែលនិយាយភាសាអង់គ្លេសជាភាសាដំបូងដែរ។

ការរៀន EAL ផ្តល់ឱ្យសិស្សនូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយនៅក្នុងភាសាអង់គ្លេស ដែលជួយពួកគេឱ្យទទួលបានជោគជ័យក្នុងគ្រប់វិស័យសិក្សា។ នៅពេលដែលគ្រូបង្រៀនរបស់កូនអ្នកវាយតម្លៃថា កូនរបស់អ្នកត្រៀមខ្លួនរួចជាស្រេចដើម្បី

ផ្លាស់ទីពី EAL ទៅភាសាអង់គ្លេសហើយនោះ ពួកគេនឹងពិភាក្សាអំពីរឿងនេះជាមួយអ្នក។ រួមគ្នា អ្នកអាចសម្រេចចិត្តលើវិធីល្អបំផុតសម្រាប់កូនរបស់អ្នកក្នុងការបន្តរៀនភាសាអង់គ្លេស។

## មាគ៌ាឆ្ពោះទៅកាន់មុខអាជីព

ការរចនាការសិក្សាវិញ្ញាបនបត្រអបរំរដ្ឋវិចថូរៀ (VCE) សម្រាប់ថ្នាក់ទី 11 និងទី 12 ក៏ផ្តល់ជូនទាំង EAL និងភាសាអង់គ្លេសផងដែរ។ សិស្សដែលបានបញ្ចប់ VCE EAL មានឱកាសដូចគ្នាក្នុងការសិក្សានៅសកលវិទ្យាល័យនៅក្នុងប្រទេសអូស្ត្រាលី ឬជ្រើសរើសមាគ៌ាសិក្សាផ្សេងទៀត ឬមុខអាជីពដូចសិស្សដែលបានបញ្ចប់ VCE ភាសាអង់គ្លេសដែរ។

## របាយការណ៍របស់សិស្ស EAL

នៅខែមិថុនា និងខែធ្នូ ជារៀងរាល់ឆ្នាំ អ្នកនឹងទទួលបានរបាយការណ៍អំពីវឌ្ឍនភាពរបស់កូនអ្នកតាមមាគ៌ាកម្មវិធីសិក្សារបស់ពួកគេ។ របាយការណ៍ EAL រួមបញ្ចូលការវាយតម្លៃសម្រាប់គំរូភាសាចំនួនបី៖ ការនិយាយ និងការស្តាប់ ការអាន និងការមើល និងការសរសេរ។ ទម្រង់គឺដូចគ្នានឹងរបាយការណ៍ភាសាអង់គ្លេសដែរ។ របាយការណ៍នេះអាចផ្តល់ព័ត៌មានបន្ថែម ជាឧទាហរណ៍ អំពីអ្វីៗដែលកូនរបស់អ្នកកំពុងធ្វើបានល្អ និងផ្នែកនានាដែលពួកគេត្រូវការជំនួយបន្ថែម។